# តើយើងត្រូវយល់ ហើយជឿយ៉ាងដូចម្ដេច ដើម្បីទទួលសេចក្ដីសង្គ្រោះពីព្រះយេស៊ូវបាន?

## ក យើងត្រូវយល់ថា តើព្រះជានរណា?

### ១ ព្រះដែលពិតប្រាកដមានតែមួយគត់ គឺជាព្រះដែលបានបង្កើតពិភពលោកទាំងមូល

គម្ពីរអេសាយ ៤៥:២២ អស់ទាំងមនុស្សនៅចុងផែនដីអើយ ចូរមើលមកអញ ហើយទទួលសេចក្ដីសង្គ្រោះចុះ ដ្បិតអញនេះជាព្រះ ឥតមាននរណាទៀតឡើយ

### ២ ព្រះបានបង្កើតមនុស្សយើងមក ដើម្បីឲ្យយើងក្លាយជាកម្មសិទ្ធិរបស់ព្រះអង្គ យើងគួរតែស្រឡាញ់ ថ្វាយបង្គំ ហើយនិងបំរើទ្រង់តែ១ប៉ុណ្ណោះ

គម្ពីរកូរិនថូសទី១ ៨:៦ មានព្រះតែ១ប៉ុណ្ណោះ គឺជាព្រះវរបិតា ដែលរបស់សព្វសារពើកើតមកពីទ្រង់ ហើយយើងរាល់គ្នាក៏សំរាប់ទ្រង់ ក៏មានព្រះអម្ចាស់តែ១ គឺជាព្រះយេស៊ូវគ្រីស្ទ ដែលរបស់សព្វសារពើកើតមកដោយសារទ្រង់ ហើយយើងក៏ដោយសារទ្រង់ដែរ

### ៣ ព្រះល្អបរិសុទ្ធ និងយុត្តិធម៌ ទ្រង់ត្រូវតែជំនុំជំរះគ្រប់ទាំងអំពើបាប និងការបះបោរប្រឆាំងនឹងព្រះ

គម្ពីរយ៉ូហានទី១ ១:៥ នេះជាដំណឹង ដែលយើងខ្ញុំបានឮពីទ្រង់ ហើយក៏ប្រាប់មកអ្នករាល់គ្នា គឺថាព្រះទ្រង់ជាពន្លឺភ្លឺ គ្មានសេចក្ដីងងឹតណា នៅក្នុងទ្រង់សោះ

## ខ យើងត្រូវយល់ថា តើមនុស្សទាំងអស់ជានរណា?

### ៤ មនុស្សទាំងអស់ជាអ្នកមានបាប ដោយសារតែបះបោរប្រឆាំងនឹងព្រះ ដោយមិនស្វែងរកព្រះដ៏ពិត

គម្ពីររ៉ូម ៣:១០-១២ ដូចមានសេចក្ដីចែងទុកមកថា គ្មានអ្នកណាសុចរិតសោះ សូម្បីតែម្នាក់ក៏គ្មានផង គ្មានអ្នកណាដែលយល់ គ្មានអ្នកណាដែលស្វែងរកព្រះ គ្រប់គ្នាបានបែរចេញ ហើយត្រឡប់ជាឥតប្រយោជន៍ទាំងអស់គ្នា គ្មានអ្នកណាដែលប្រព្រឹត្តតាមសេចក្ដីសប្បុរសសោះ តែម្នាក់ក៏គ្មានផង

### ៥ ឈ្នួលនៃអំពើបាបរបស់មនុស្សយើង គឺជាសេចក្ដីស្លាប់ ហើយនិងការដាច់ចេញពីព្រះ នៅឋាននរកអស់កល្បជានិច្ច

គម្ពីរវិវរណៈ ២១:៨ តែត្រង់ពួកខ្លាច ពួកមិនជឿ ពួកគួរខ្ពើម ពួកកាប់សំឡាប់គេ ពួកកំផិត ពួកមន្តអាគម ពួកថ្វាយបង្គំរូបព្រះ ហើយគ្រប់ទាំងមនុស្សកំភូត គេនឹងមានចំណែកនៅក្នុងបឹងដែលឆេះជាភ្លើងនិងស្ពាន់ធ័រ គឺជាសេចក្ដីស្លាប់ទី២វិញ

## គ យើងត្រូវយល់ថា តើព្រះយេស៊ូវជានរណា?

៦ ទោះបីជាមនុស្សយើងជាអ្នកមានបាបប្រឆាំងនឹងព្រះក៏ដោយ ព្រះនៅតែស្រឡាញ់មនុស្ស ទ្រង់បានយាងមកពីឋានសួគ៌ ចាប់កំណើតជាមនុស្ស ដើម្បីសង្គ្រោះមនុស្សយើងឱ្យរួចពីបាប

គម្ពីររ៉ូម ៥:៨ តែឯព្រះ ទ្រង់សំដែងសេចក្តីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឱ្យឃើញច្បាស់ ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង

៧ ព្រះយេស៊ូវបានសងថ្លៃលោះបាបរបស់មនុស្សយើង ដោយទ្រង់បានសុគតនៅលើឈើឆ្កាង

គម្ពីរពេត្រុសទី១ ២:២៤ ទ្រង់បានផ្ទុកអំពើបាបរបស់យើងរាល់គ្នា នៅលើរូបអង្គទ្រង់ជាប់លើឈើឆ្កាង ដើម្បីឱ្យយើងបានរស់ខាងឯសេចក្តីសុចរិត ដោយបានស្លាប់ខាងឯអំពើបាបហើយ គឺដោយស្នាមជាំរបស់ទ្រង់ ដែលអ្នករាល់គ្នាបានជា

៨ ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ហើយមានជ័យជំនះលើសេចក្តីស្លាប់

គម្ពីររ៉ូម ១:៤ តែខាងឯព្រះវិញ្ញាណនៃសេចក្តីបរិសុទ្ធ នោះបានសំដែងមកច្បាស់ថា ទ្រង់ជាព្រះរាជបុត្រារបស់ព្រះពិត ទាំងមានព្រះចេស្តាផង ដោយទ្រង់បានរស់ពីស្លាប់ឡើងវិញ គឺជាព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា

## ឃ យើងត្រូវយល់ថា តើដំណឹងល្អគឺជាអ្វី?

៩ អស់អ្នកណាដែលកែប្រែចិត្តពីអំពើបាបរបស់ខ្លួន ហើយជឿទុកចិត្តលើព្រះយេស៊ូវ នោះនឹងទទួលបានសេចក្តីសង្គ្រោះ

គម្ពីរថែស្សាឡូនីចទី១ ១:៩-១០ ទាំងបែរចេញពីរូបព្រះ មកឯព្រះដ៏ពិត ឱ្យបានគោរពប្រតិបត្តិដល់ព្រះ ដ៏មានព្រះជន្មរស់នៅនោះវិញ ហើយឱ្យបានចាំព្រះរាជបុត្រាព្រះ ទ្រង់យាងមកពីស្ថានសួគ៌ ដែលព្រះបានប្រោសឱ្យទ្រង់រស់ពីស្លាប់ឡើងវិញ គឺជាព្រះយេស៊ូវ ដែលទ្រង់ប្រោសឱ្យយើងរួចពីសេចក្តីខ្ញាល់ទៅមុខ

១០ ព្រះបានសន្យាអត់ទោសបាបឱ្យយើង ហើយប្រទានមរតកឱ្យយើង ដែលឋិតថេរអស់កល្បជានិច្ច

គម្ពីរកិច្ចការ ២៦:១៨ ប្រយោជន៍នឹងបំភ្លឺភ្នែកគេ ឱ្យបានបែរចេញពីសេចក្តីងងឹត មកឯពន្លឺ ហើយពីអំណាចអារក្សសាតាំង មកឯព្រះវិញ ដើម្បីឱ្យគេបានរួចពីបាប ហើយបានទទួលមរតកជាមួយនឹងពួកអ្នកដែលបានញែកជាបរិសុទ្ធ ដោយសារសេចក្តីជំនឿជឿដល់ខ្ញុំ